ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Sep-2012, 16:00
CMS/CFO: Krystal THOMPSON

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

## ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើធ្វើឡើងដោយ អៀង សារី និង នួន ជា សុំប្រើប្រាស់សម្ភារៈឯកសារក្នុងអំឡុងពេលសួរដេញដោល PHILIP SHORT

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា

លោកស្រី ជា លាង

លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រមJean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:

ពេជ អង្គ

Elisabeth SIMONNEAU FORT

**ចម្លងជូន:**

ជនជាប់ចោទ

នួន ជា

អៀង សារី

ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor Koppe

លោក អាង ឧត្តម

លោក Michael G.KARNAVAS

លោក គង់ សំអុន

Anta GUISSÉ
លោក Arthur VERCKEN
លោក Jacques VERGÈS

## I. សេចក្តីផ្តើម

១. ក្រុមមេធាវីការពារក្តី អៀង សារី និង នួន ជា បានដាក់សំណើជូនអង្គជំនុំជម្រះសាលាដំបូង សុំប្រើឯកសារជាក់លាក់មួយចំនួន (“ឯកសារ”) ក្នុងពេលសួរដេញដោលលោក Philip Short ជាអ្នកដែលត្រូវបានកំណត់ពេលមកផ្តល់សក្ខីកម្មដោយចាប់ផ្តើមនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១២[1] នេះ។ ដោយសារ ជាបញ្ហានៃគោលការណ៍ សហព្រះរាជអាជ្ញាមិនមានគោលជំហរដែលថា ក្រុមមេធាវីការពារក្តី គួរតែត្រូវបានច្រានចោលជាមុន ដោយមិនឲ្យស្វែងរកនូវការពឹងផ្អែកទៅលើឯកសារទាំងនេះទេ ដោយហេតុ ថា (ក) ឯកសារទាំងនេះ អាចឲ្យគេរកបានតាំងពីមុនសវនាការបានចាប់ផ្តើម និង/ឬ (ខ) ឯកសារ មិនត្រូវបានដាក់បញ្ចូលក្នុងបញ្ជីឯកសារតាមវិធាន ៨០ ដែលបានដាក់ជូននៅមុនពេលចាប់ផ្តើម សវនាការ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការជូនដំណឹងឲ្យបានគ្រប់គ្រាន់កំពុងត្រូវបានផ្តល់ជូនទៅគ្រប់ភាគីទាំងអស់ហើយ ដែល ឯកសារនិមួយៗគួរត្រូវបានពិនិត្យដើម្បីកំណត់ថាតើ វាមានផ្ទុកនូវឯកសារ ពាក់ព័ន្ធឬទេ ហើយថាតើ ឯកសារ ទាំងនោះត្រូវលើយកមកដើម្បីសួរដេញដោលលោក Short ឲ្យបានត្រឹមត្រូវ។ សេចក្តីសន្និដ្ឋានជាក់លាក់ទាក់ទងនឹងឯកសារនិមួយៗទាំងនេះមានចែងដូចខាងក្រោម។

## II. ឯកសារដែលបានស្នើសុំដោយមេធាវីការពារក្តី អៀង សារី

*ការតស៊ូមតិរបស់ក្រុមបីសាច: មិនគួរមានតុលាការកាត់ទោសខ្មែរក្រហម*

២. មេធាវីការពារក្តីអះអាងថា ឯកសារនេះ “មានភាពពាក់ព័ន្ធពីព្រោះវាបាននិពន្ធឡើងដោយលោក SHORT និងបញ្ចេញទស្សនៈរបស់លោកលើបញ្ហាផ្សេងៗដែលជាប់ទាក់ទិននឹងសំណុំរឿង ០០២/១ មានដូចជា ចេតនារបស់មេដឹកនាំជាន់ខ្ពស់ទាក់ទងនឹងចាម ហើយនឹងការជាប់ទាក់ទងទៅនឹងមន្ទីរស-២១”។ សហព្រះរាជអាជ្ញាសន្និដ្ឋានថាបញ្ហាចេតនា គឺជារឿងដែលអង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការកំណត់សម្រេចស្តាប់គ្រប់ភ័ស្តុតាងទាំងអស់។ វាជា “បញ្ហាចុងក្រោយបង្អស់” ក្នុងករណីនេះ វាមិនមែនទាក់ទិននឹងអ្វីដែលជាមតិរបស់លោក Short នឹងជួយដល់តុលាការ

[1] **E226** “សំណើតាមវិធាន ៨៧ សុំប្រើប្រាស់ឯកសារក្នុងអម្លុងពេលសួរដេញដោលសាក្សី PHILIP SHORT” (មេធាវីការពារក្តី នួន ជា); **E226/1** “សំណើរបស់ អៀង សារី អនុលោមតាមវិធាន៨៧(៤) ពាក់ព័ន្ធនឹងសម្ភារៈឯកសារដែលអាចនឹងយកមកប្រើក្នុងអម្លុងពេលសួរដេញដោលអ្នកជំនាញ PHILIP SHORT”។

នោះទេ។ ក្នុងខណៈដែលក្រុមមេធាវីការពារក្តីអាចធ្វើសួរលោក Philip Short នូវសំណួរ ផ្សេងៗ អំពីរឿងនយោបាយ និងសកម្មភាពទាំងឡាយរបស់បក្សកុម្មុយនីសកម្ពុជា (បកក) និងរបបកម្ពុជាប្រជាធិតេយ្យទាក់ទងជនជាតិចាម តែមិនអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីសួរ លោក Philip Short ឲ្យបញ្ចេញទស្សនៈអំពី: (i) ថាតើជនជាប់ចោទមានចេតនាប្រល័យពូជសាសន៍ចាំបាច់ទាក់ទងនឹងប្រជាជនចាមដែរឬអត់ ឬ (ii) ទាក់ទងនឹងប្រជាជនចាមដដែល ថាតើសកម្មភាពផ្សេងៗរបស់របបនេះ រួមបង្កើតបានជាអំពើប្រល័យពូជសាសន៍ ដែរឬអត់នោះទេ។ ការព្យាយាមដើម្បីទាញយកមតិរបស់លោក Philip Short លើបញ្ហានេះ គឺជាការដណ្តើមតួនាទីរបស់តុលាការ។ សំណួរដូច្នេះមិនអាចអនុញ្ញាតឡើយ ដោយហេតុថា វាមិនសំដៅទៅលើអង្គហេតុនៃរឿងក្តីនេះ តែជាបញ្ហានៃការទទួលខុសត្រូវ និងជាតួនាទីតែមួយគត់ដែលបានរក្សាទុកឲ្យតុលាការនេះ។

៣. ចំពោះ មន្ទីរស-២១ សហព្រះរាជអាជ្ញា សូមលើកជាយោបល់ថាដូចគ្នានឹងលោកសាស្ត្រាចារ្យ Chandler ដែរ គឺលោក Philip Short អាចនឹងត្រូវបានគេសួរសំនួរផ្សេងៗ ផ្អែកលើមូលដ្ឋាននៃការសិក្សាស្រាវជ្រាវ និងការដឹងឮរបស់គាត់អំពីអង្គហេតុនានា ដូចជាអំពីការទំនាក់ទំនងរវាងជនជាប់ចោទ និងមន្ទីរស-២១ ។ នៅក្នុងអត្ថបទនេះ ត្រូវបាននិពន្ធនៅក្នុងឆ្នាំ២០០០ (នៅមុនការបោះពុម្ពផ្សាយសៀវភៅរបស់គាត់ស្តីពីបក្សកុម្មុយនីស្តកម្ពុជា (CPK) និងកម្ពុជាប្រជាធិបតេយ្យ (DK) ) លោក Short បានថ្លែងថា៖

> *គ្មាននរណាម្នាក់អាចប្រកែកបានដោយសមហេតុសមផលថា នួន ជា ជាអ្នកទទួលខុសត្រូវលើបញ្ហាសន្តិសុខទាំងមូល ចំណែកឯ សុន សេន វិញទទួល ខុសត្រូវដោយផ្ទាល់លើមន្ទីរស-២១។ មេដឹកនាំដទៃទៀតក៏សុទ្ធតែបានដឹង អំពីថាតើអ្វីខ្លះបានកើតមានឡើងនៅទីនោះដែរ ហើយដោយសារថាពួកគាត់គឺជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃ បកក នោះ យ៉ាងហោចក៏ពួកគាត់ធ្លាប់បានចូលរួមចំណែកនៅក្នុងការចាត់វិធានការណ៍ ដោយទទួលខុសត្រូវជាសមូហភាពនៅក្នុងនោះដែរ។*

សហព្រះរាជអាជ្ញាឯកភាពថា មេធាវីគួរត្រូវបានអនុញ្ញាតឲ្យធ្វើការតាំងសំនួរដេញដោលលោក Short ដើម្បីឲ្យលោកធ្វើការអត្ថាធិប្បាយថែមទៀតអំពីបញ្ហានេះ។

## III. ឯកសារដែលបានស្នើសុំដោយមេធាវីការពារក្តី នួន ជា

*ក. អត្ថបទនិពន្ធដោយ Blythe Yee, ដែលមានចំណងជើងថា៖ "ការបើកបរនៅក្នុងភាពខ្មៅងងឹត" 'Navigating Darkness', កាសែត Asian Wall Street Journal, ចុះផ្សាយ ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៥*

៤. អត្ថបទនេះក្នុងពេលបច្ចុប្បន្នមានតែជាភាសាបារាំង ហើយវាហាក់ដូចជាមានតែសេចក្តីសង្ខេបនៃអត្ថបទនោះប៉ុណ្ណោះ ដែលមានរាយនៅក្នុងបញ្ជីនៅក្រោមអនុកថាខណ្ឌ "ខ"។ អត្ថបទនេះកំពុងតែត្រូវបានដាក់ឲ្យបកប្រែទាំងមូល សហព្រះរាជអាជ្ញា មិនជំទាស់ទេ ក្នុងការប្រើ ប្រាស់នូវអត្ថបទនេះ សម្រាប់មូលហេតុដូចគ្នាដូចដែលបានលើកឡើងនៅក្រោម អនុកថាខណ្ឌ "ខ" ខាងក្រោម។

*ខ. Charlie Rose (ប្រតិចារិកនៃការធ្វើសម្ភាសន៍ជាមួយលោក Philip Short), ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៥*

៥. សហព្រះរាជអាជ្ញា មិនជំទាស់ទេ ក្នុងការប្រើប្រាស់នូវឯកសារនេះ ហើយដាក់សារណាដដែល ត្រង់កថាខណ្ឌទី២ខាងលើ មកម្តងទៀត។ នៅក្នុងអម្លុពេលធ្វើសម្ភាសន៍នោះលោក Philip Short បានធ្វើសេចក្តីអធិប្បាយផ្សេងៗស្តីពីការទទួលខុសត្រូវរបស់ លោក ជា ស៊ីម ដោយបានថ្លែងថា ជា ស៊ីម "ដៃគាត់មានប្រឡាក់ឈាម"។ ដើម្បីបង្ការទុកជាមុននូវការជំទាស់ណាមួយចំនួនដែលអាចនឹងត្រូវបានលើកឡើងសំនួរទាក់ទងអំពី ជា ស៊ីម មេធាវីការពារក្តីគួរតែត្រូវបានធ្វើការណែនាំ ដើម្បីឲ្យបញ្ជាក់ថាតើពួកគេមានបំណងចង់សួរដេញដោលលោក Philip Short លើប្រធានបទនេះដែរឬទេ? និងដើម្បីធ្វើយុត្តិកម្មអំពីកម្រិតនៃការជាប់ទាក់ទងនៃសំនួរទាំងនេះទៅនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទនៅក្នុងសវនាការនេះ។

*គ. Brendan Brady, "កម្ពុជាប្រឈមនឹងពាក្យ G " ('Cambodia confronts the 'G" Word'), គោលនយោបាយក្រៅប្រទេស, ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១០*

៦. ដោយសារមូលហេតុដូចបានជំរាបជូនក្នុងកថាខណ្ឌទី២ ខាងលើ សហព្រះរាជអាជ្ញាសន្និដ្ឋានថាមតិរបស់លោក Short អំពីភាពសមស្របនៃបទចោទប្រកាន់នៃអំពើប្រល័យពូជសាសន៍ គឺជាការដណ្តើមយកមុខនាទីរបស់អង្គជំនុំជម្រះ ហើយវាក៏មិនមែនជាបញ្ហាសមស្រប និងពាក់ព័ន្ធដែរ

សម្រាប់មតិរបស់អ្នកជំនាញ។ ទន្ទឹមនេះ សហព្រះរាជអាជ្ញាសូមជំទាស់នឹងការប្រើប្រាស់ឯកសារនេះ។

*ឃ. "អតីតមេខ្មែរក្រហម ត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍" Press TV, ផ្សាយថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩*

៧. សេចក្តីយោងតែមួយរបស់ លោក Short គឺមានដូចតទៅ៖

*លោក Philip Short ដែលជាអ្នកនិពន្ធសៀវភៅជីវប្រវត្តិរបស់ ប៉ុល ពត បាន ហៅបទចោទប្រកាន់ថា "បានកាត់យល់ខុស និង មិនមានប្រយោជន៍" - "ហេតុអ្វីបានជាធ្វើទឹកឲ្យល្អក់ ដោយការនាំយកនូវបទចោទដែលមានមន្ទិល មក បណ្តាលឲ្យអង្គជំនុំជម្រះរឹតតែជាប់គាំងបន្ថែមទៀតតែប៉ុណ្ណោះ? ឱ! អនិច្ចាអើយ សេចក្តីល្ងង់ខ្លៅនេះ និងគំនិតដ៏ច្រឡំបល់តាមបែបមួយនេះ បានចារឹកលក្ខណៈឲ្យអង្គជំនុំជម្រះនេះតាំងពីដើមដំបូងមកម្ល៉េះ។*

៨. ទស្សនៈរបស់លោក Short ទាក់ទងទៅនឹងបទចោទ គឺ មិនមានការពាក់ព័ន្ធណាមួយឡើយ។ អវត្តមានយុត្តិកម្មបន្ថែមទៀតពីមេធាវីការពារក្តី ទាក់ទងនឹងរបៀបដែលគេអាច តាំងសំនួរដល់ លោក Short ដែលមានមូលដ្ឋាននៅលើខ្លឹមសារនៃឯកសារនេះ សហព្រះរាជអាជ្ញាសូមជំទាស់ទៅនឹងការប្រើប្រាស់របស់វា ដោយលើទឡ្ហីករណ៍ពីភាពមិនមានជាប់ពាក់ព័ន្ធ។ ក្នុងព្រឹត្តិការណ៍ណាក៏ដោយ សហព្រះរាជអាជ្ញាសូមដាក់ជូននូវសេចក្តីសន្និដ្ឋានរបស់ខ្លួនដដែល ត្រង់កថាខណ្ឌទី២ ខាងលើ។

*ង. "ម៉ៅ សេទុង មិនបានរៀបចំ Philip Short សម្រាប់ ប៉ុល ពត ទេ"*

៩. ឯកសារនេះមានសម្ភារៈពាក់ព័ន្ធទាក់ទងទៅនឹងវិធីសាស្ត្រក្នុងការស៊ើបអង្កេតដែល លោក Short បានប្រើប្រាស់នៅក្នុងការស្រាវជ្រាវសៀវភៅរបស់គាត់ "ប៉ុល ពត៖ កាយវិភាគសាស្ត្រអំពីសុបិនអាក្រក់មួយ" (Pol Pot: Anatomy of a Nightmare) ហើយសហព្រះរាជអាជ្ញា មិនជំទាស់ទៅនឹងការសួរដេញដោលពីសៀវភៅនេះទេ។

១០. សហព្រះរាជអាជ្ញាកត់សំគាល់បន្ថែមថា ឯកសារដែលបានស្នើឡើងដោយមេធាវីការពារក្តី នួន ជា ហាក់ដូចជាឯកសារដែលពួកគេបានរៀបចំឡើង ជាជាងអត្ថបទច្បាប់ដើម។ មុនពេលឯកសារណាមួយនៃឯកសារទាំងនេះត្រូវបានប្រើប្រាស់នៅក្នុងតុលាការ មេធាវីការពារក្តី នួន ជា គួរតម្រូវឲ្យធ្វើការពន្យល់ពីរបៀបដែលឯកសារទាំងនេះត្រូវបានរៀបចំឡើង ពីប្រភពដែលទទួលបានអត្ថបទ និងប្រតិចារឹកដូចដែលគេបានអះអាង ឬព័ត៌មានផ្សេងទៀតឲ្យបានគ្រប់គ្រាន់ដើម្បីធានាអំពីយថាភូត និងភាពជឿទុកចិត្តបានចំពោះឯកសារទាំងនេះ។

## IV. ការជូនដំណឹងអំពីសំណើរបស់សហព្រះរាជអាជ្ញា តាមវិធាន ៨៧(៤)

១១. សហព្រះរាជអាជ្ញា ផ្តល់ការជូនដំណឹងជាមុនស្តីពីបំណងរបស់ខ្លួនក្នុងការធ្វើសំណើរបស់ខ្លួន តាមវិធាន៨៧.៤ ទាក់ទងទៅនឹងការថតជាខ្សែវីឌីអូនៃបាឋកថាដែលបានផ្តល់ដោយលោក Short នៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៥ នៅសាកលវិទ្យាល័យ California, ទីក្រុង Los Angeles, ប្រទេសសហរដ្ឋអាមេរិក។ បាឋកថានេះអាចរកបាននៅតាមគេហទំព័របណ្ណាល័យវីឌីអូ (www.c-spanvideo.org)។ វាមានរយៈពេលប្រមាណជា ៩១នាទី ហើយមានការពិភាក្សាគ្នាមួយធ្វើឡើងដោយ លោក Short ស្តីពីការស្រាវជ្រាវលំអិត និង របកគំហើញនានាទាក់ទងទៅនឹងប្រវត្តិសាស្ត្ររចនាសម្ព័ន្ធ និង គោលនយោបាយផ្សេងៗរបស់ បកក និងកម្ពុជាប្រជាធិបតេយ្យ។ បាឋកថាដែលសហព្រះរាជអាជ្ញា ទើបតែបានដឹងនៅពេលថ្មីៗនេះ គឺគេអាចមើលបាន ក៏ប៉ុន្តែគេមិនអាចទាញយកចេញមកបាន (cannot be downloaded) នៅពេលបច្ចុប្បន្ននេះទេ។ សំណើបន្ទាន់មួយត្រូវបានធ្វើទៅកាន់អ្នកប្រតិបត្តិគេហទំព័រ ដើម្បីឲ្យបានមកនូវសំណៅចម្លងមួយច្បាប់នៃការថតជាខ្សែវីឌីអូនេះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ | **លោក យ៉េត ចរិយា** សហព្រះរាជអាជ្ញារង | ភ្នំពេញ | [signature] |
| | **លោក William SMITH** សហព្រះរាជអាជ្ញារង | | [signature] |